ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ
## របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

*****

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៨៣ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- តាមការអនុម័តគណៈរដ្ឋមន្ត្រីនាថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៩៧

## សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.- អនុក្រឹត្យនេះរៀបចំបណ្ដាអង្គភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២.- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌ និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមានមុខងារ និងភារកិច្ចដូចតទៅ :

- ប្រតិបត្តិទូទៅលើការពារ ថែរក្សា និងលើកតម្លៃបេតិកភណ្ឌ វប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងបណ្ដារមណីយដ្ឋាន បុរាណវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា
- ស្ដារឡើងវិញនិងលើកតំកើងបណ្ដាតំលៃវប្បធម៌ និងជំនឿជំនៀមទម្លាប់ប្រពៃណីរបស់សហគមជាតិ បំផុសការបង្កើតស្នាដៃ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ សកម្មភាពវប្បធម៌
- ជាអាណាព្យាបាលលើសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងការបណ្ដុះបណ្ដាល សិល្បករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹង វិស័យវប្បធម៌ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរចនាសម្ព័ន្ធដូចតទៅ :

ក. នៅថ្នាក់កណ្ដាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- នាយកដ្ឋានសិល្បៈ និង ទស្សនីយភាព
- នាយកដ្ឋានបេតិកភណ្ឌ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

ខ. អង្គភាពមូលដ្ឋាន

- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង
- ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ស្រុក ខណ្ឌ ។

អង្គការលេខរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូក ៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥.-ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបំពេញភារកិច្ចទាំងឡាយ ដែលកំណត់តាមមុខងារបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៦ ដូចមានចែងក្នុងរបៀបរបបទូទៅនៃសេចក្តីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង អគ្គលេខាធិការដ្ឋាន ។

## ជំពូក ៤

## អធិការដ្ឋាន

មាត្រា ៦.-អធិការដ្ឋានរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទទួលបន្ទុក :

-ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

-ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ជូនពិសេស

អធិការដ្ឋានដឹកនាំដោយអធិការមួយនាក់ អមដោយអធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់

## ជំពូក ៥

## - នាយកដ្ឋានសិល្បៈ – ទស្សនីយភាព

មាត្រា ៧.-នាយកដ្ឋានសិល្បៈ ទស្សនីយភាព ទទួលបន្ទុក :

-លើកទឹកចិត្តការបង្កើតស្នាដៃធ្វើឱ្យសំបូរបែប ព្រមទាំងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវទស្សនីយភាពរស់ មានវិស័យល្ខោន ភ្លេង របាំ សៀក និងទស្សនីយភាពផ្សេងៗទៀត

-កំណត់នូវគោលនយោបាយបច្ចេកទេសជំនាញសិល្បៈ ចំពោះបណ្តាក្រុមសិល្បៈតាមខេត្ត ក្រុងទូទាំងប្រទេស

-សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងការបណ្តុះបណ្តាលអ្នកជំនាញការនៃវិស័យសិល្បៈរស់ .

-លើកឡើងនូវគោលនយោបាយពីការលើកតម្កើង និង ការកែលម្អរបបល្អប្រសើរជីវភាព និងការរៀបចំ វិស័យសិល្បៈ

-សិក្សាអំពីសកម្មភាពទាំងឡាយសំដៅ ពង្រីកទស្សនីយភាព ។

នាយកដ្ឋានសិល្បៈ-ទស្សនីយភាព ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាន នាយកដ្ឋានមួយចំនួន តាមតម្រូវការចាំបាច់ ។

## ជំពូក ៦

## នាយកដ្ឋានបេតិកភណ្ឌ

មាត្រា ៨.- នាយកដ្ឋានបេតិកភណ្ឌទទួលបន្ទុក ៖

- សិក្សាការពារកេរ្តិ៍ និង ធ្វើឲ្យមានតំលៃចំពោះរាល់ផ្នែកនៃបេតិកភណ្ឌវប្បធម៌ជាតិ ពិសេសចំពោះបេតិកភណ្ឌនៃវិមានទីនិងបុរាណវិទ្យា វត្ថុជាប្រវត្តិសាស្ត្រសម្បត្តិវប្បធម៌ បេតិកភណ្ឌនៃជាតិពិពិធវិទ្យា និង បណ្តារមណីយដ្ឋានដែលត្រូវការពារ ក្រោមអាណាព្យាបាលប្រជាជាតិ និង [illegible] ។
- រៀបចំផែនទី ផ្នែកវប្បធម៌សំដៅអនុវត្តកម្មវិធីនៃការធ្វើទីពិសោធវប្បធម៌នៅទូទាំងប្រទេស ។

នាយកដ្ឋានបេតិកភណ្ឌមានដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូក ៧

## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៩.- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានមុខងារដូចតទៅ ៖

- គ្រប់គ្រងការងាររួមមាន ៖ រដ្ឋបាល_បូកសរុប_ផែនការណ៍_ឯកសារ_បុគ្គលិក_ផែនការហិរញ្ញវត្ថុ_សម្ភារៈបរិក្ខារ_ការងារបណ្តុះបណ្តាលក្របខ័ណ្ឌក្រសួង_ការងារសិក្សាស្រាវជ្រាវ និងធ្វើទំនើបភាពការងារ ។

- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពរដ្ឋបាលខេត្ត-ក្រុង និងជាមួយបណ្តាក្រសួងនានា ។

មាត្រា ១០.- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជួយធ្វើការងារតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាននាយកដ្ឋានចំណុះចំនួន ៥ និងសាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ផ្ទាល់ស្មើនាយកដ្ឋាន ៖

១. នាយកដ្ឋានរដ្ឋបាលទូទៅ
២. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៣. នាយកដ្ឋានសម្ភារៈ និងបរិក្ខារ
៤. នាយកដ្ឋានសិក្សាស្រាវជ្រាវ និងពុម្ពភាពការងារ
៥. នាយកដ្ឋានបុគ្គលិក
៦. សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ។

មាត្រា ១១.- នាយកដ្ឋានរដ្ឋបាលទូទៅទទួលបន្ទុក :

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្ដាល និងរវាងថ្នាក់កណ្ដាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

មាត្រា ១២.- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុទទួលបន្ទុក :

- ប្រមូលចំណូល ឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- លើកគំរោងថវិកាក្រសួង និងតាមដានលើកពីការប្រតិបត្តិ
- ប្រមូលផ្ដុំ និងសម្របសម្រួលជំពូកថវិកា
- តាមដានលើកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្ដុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

មាត្រា ១៣.- នាយកដ្ឋានសម្ភារៈ និងបរិក្ខារទទួលបន្ទុក :

- ប្រមូលផ្ដុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្ដាអង្គភាពខេត្ត-ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

មាត្រា ១៤.- នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគុណភាពការងារទទួលបន្ទុក :

- ធ្វើឱ្យសំរេច និងផ្សព្វផ្សាយនូវការងារសិក្សា ស្រាវជ្រាវ និងបូកសរុបដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ចនៃវិស័យវប្បធម៌ ព្រមទាំងផ្ទៀងផ្ទាត់ការប្រើប្រាស់បានល្អនូវបណ្ដាលទ្ធផលទាំងនោះ
- សិក្សាពិចារណាលើវិធីសាស្ត្រធ្វើការងារក្នុងក្រសួង ព្រមទាំងលើកសំណើផ្សេងៗដើម្បីកែសម្រួល
- រៀបចំគំរោងផែនការអំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ និងសុំជំនួយឧបត្ថម្ភផ្សេងៗ
- សហការជាមួយក្រសួងផែនការ ដើម្បីរៀបចំប្រព័ន្ធស្ថិតិមួយ អំពីជីវភាពវប្បធម៌ទាំងប

ប្រទេស

-រៀបចំចងក្រងកម្មវិធីវប្បធម៌ សំរាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍ ។

មាត្រា ១៥.- នាយកដ្ឋានបុគ្គលិកទទួលបន្ទុក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនិងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីពិតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតំលៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

-រៀបចំនយោបាយបណ្តុះបណ្តាលថ្មីៗ និងបន្តដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

-គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

មាត្រា ១៦.- សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ( ដោយធ្វើទំនាក់ទំនងជាមួយសាលាភូមិន្ទរដ្ឋបាល) ទទួលបន្ទុក :

-រៀបចំការប្រលងជ្រើសរើសបញ្ចូលក្របខ័ណ្ឌក្រសួង ឱ្យសមស្របតាមនយោបាយបុគ្គលិករបស់ក្រសួង

-ធ្វើការបណ្តុះបណ្តាលទូមុខវិជ្ជាជំនាញចាំបាច់ មុនបញ្ចូលជាក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង

-រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង

-រៀបរៀងកម្មវិធីសិក្សាសមស្រប តាមការរៀបចំក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង ។

## ជំពូក ៤

## អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

មាត្រា ១៧.- អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មានមុខងារអនុវត្តទូរាល់បេសកកម្ម របស់ក្រសួង ក្នុងការប្រតិបត្តិនយោបាយលើវិស័យ :

បេតិកភណ្ឌ សារៈមន្ទីរ សិល្បៈលូនរូប សៀវភៅ និងការអានសាធារណៈ ភាពយន្តវីដេអូ និង ពហុមេឌិយ៉ា អភិវឌ្ឍន៍វប្បធម៌ និង អប់រំសិល្បៈ ។

មាត្រា ១៨.- អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន ជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានបច្ចេកទេស មាននាយកដ្ឋានចំណុះចំនួន ៥ :

១.នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌

២.នាយកដ្ឋាន សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌

៣_នាយកដ្ឋាន សារៈមន្ទីរ

៤_នាយកដ្ឋាន សិល្បៈសូន្យរូប និង សិប្បកម្ម

៥_នាយកដ្ឋាន សៀវភៅ និងការអាន ។

មាត្រា ១៩.- នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌ទទួលបន្ទុកៈ

_លើកទឹកចិត្តពលសកម្មភាពវប្បធម៌ ព្រមទាំងរៀបចំតាក់តាំងបណ្តាការសំដែងសិល្បៈ វប្បធម៌ ពិពណ៌សំដៅធ្វើឱ្យមហាជន ចាប់អារម្មណ៍នឹងវប្បធម៌របស់ខ្លួន

_បំផុសនិងសម្រួលសមាគមវិជ្ជាជីវៈផ្សេងៗ ក្នុងវិស័យវប្បធម៌សំដៅលើកកំពស់មនសិការ វិជ្ជាជីវៈ ព្រមទាំងការពារផលប្រយោជន៍ស្របច្បាប់របស់គេ

_លើកទឹកចិត្ត និងត្រួតពិនិត្យចំពោះការថែរក្សា ពលសកម្មភាពវប្បធម៌ល្អៗ របស់ប្រជាពលរដ្ឋតាមតំបន់ទូទាំងប្រទេស ។

មាត្រា ២០.- នាយកដ្ឋាន សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ទទួលបន្ទុក :

_តំរង់ទិស និង លើកទឹកចិត្តក្នុងការផ្សព្វផ្សាយវប្បធម៌និងសិល្បៈ តាមភាពយន្ត វីដេអូ និងពហុមេឌីយ៉ា

_សិក្សា និងអនុញ្ញាតការធ្វើអាជីវកម្មសិល្បៈទិដ្ឋ ជាភាពយន្ត និង វីដេអូ

_រក្សាឯកសារភាពយន្ត និងវីដេអូជាតិ

_អនុញ្ញាតនិងលើកទឹកចិត្ត ធ្វើឱ្យអភិវឌ្ឍន៍សិល្បៈទិដ្ឋ ក្នុងរូបភាពជាភាពយន្តនិងវីដេអូ

_ផលិតផ្សព្វផ្សាយគ្រប់គ្រង និងត្រួតពិនិត្យវិស័យវប្បធម៌តាមរូបភាព ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា ដោយសហការជាមួយក្រសួងពាក់ព័ន្ធ

_បណ្តុះបណ្តាល បំពាក់បំប៉នមុខជំនាញភាពយន្ត និង វីដេអូ ។

មាត្រា ២១.- នាយកដ្ឋាន សារៈមន្ទីរ ទទួលបន្ទុក :

-គ្រប់គ្រងការអភិរក្ស ការថែរក្សា ការជួសជុល ការសិក្សា និងការធ្វើឱ្យសំបូរបែបនៃសម្បត្តិសាធារណៈ ។

_ធានាការផ្សព្វផ្សាយ និងការតាំងបង្ហាញសម្បត្តិទាំងឡាយ ចំពោះសាធារណៈជនព្រមទាំងត្រួតពិនិត្យ តាមលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បណ្តាសម្បត្តិទាំងនោះ ។

_ជាអាណាព្យាបាលលើសារៈមន្ទីររដ្ឋ និងសារៈមន្ទីរគ្រប់ប្រភេទនៅទូទាំងប្រទេស ។

មាត្រា ២២.-នាយកដ្ឋានសិល្បៈសូន្យរូប និងសិប្បកម្មទទួលបន្ទុកតំរង់ទិសបំផុសការបង្កើតស្នាដៃនិងលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃ ព្រមទាំងផ្សព្វផ្សាយក្នុងចំណោមមហាជននូវរាល់រូបភាពសិល្បៈសូន្យរូប និងសិប្បកម្មសិល្បៈ ។

មាត្រា ២៣.- នាយកដ្ឋានសៀវភៅ និងការអាន ទទួលបន្ទុក :

- ថែរក្សាការពារ និងលើកតំកើងកល់ស្នាដៃសរសេរ ដែលបានរក្សាទុក និងតំកល់ទុក តាមច្បាប់ ។
- ទ្រទ្រង់ចំពោះសៀវភៅគ្រប់ប្រភេទ បង្កលក្ខណៈងាយស្រួលក្នុងការបង្កើតចេញជាសៀវភៅ និងជួយគាំពារចំពោះការផ្សព្វផ្សាយ
- ធ្វើឲ្យសៀវភៅទៅដល់មនុស្សគ្រប់រូប តាមរយៈការអានជាសាធារណៈ
- គ្រប់គ្រងបណ្ណាល័យជាតិ និងបណ្ណាល័យនៅតាមខេត្ត
- អនុញ្ញាតឲ្យបើក និងត្រួតពិនិត្យបណ្ណាគារគ្រប់ប្រភេទ ។

## ជំពូក ៩

## សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

មាត្រា ២៤.- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានមុខងាររៀបចំការបណ្តុះបណ្តាលសិល្បករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ ។

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានឋានៈសមមូលអគ្គនាយកដ្ឋាន ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នឹងត្រូវរៀបចំដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូក ១០

## អង្គភាពមូលដ្ឋាន

មាត្រា ២៥.- នៅតាមខេត្ត-ក្រុងនីមួយៗមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុងមួយ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង ។

## ជំពូក ១១

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២៦.- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញត្តិកំណត់ ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១២

## អវសានបញ្ញត្តិ

មាត្រា ២៧.- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅថ្នាក់កណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ២៨.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៩.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ទី ១៤ ខែ តុលា ឆ្នាំ១៩៩៧

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| អ៊ុង ហួត | ហ៊ុន សែន |

បានជំរាបជូនឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
សម្ដេចនាយករដ្ឋមន្ត្រីទី ២

នុត ណារ៉ាង
រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ: ចល
បានឃើញ និងបញ្ជូនមក
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង
"ដើម្បីជ្រាប"
ភ្នំពេញថ្ងៃទី ខែ ឆ្នាំ ១៩៩៧
ត.ប រដ្ឋមន្ត្រី

ចំលងជូន :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន [illegible]
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ២៩
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧២អនក្រ.ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៩៧
# អង្គការលេខរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

